Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 5/1 (October 2004): 103–12



# Abigail, the Peacemaker

*Linda VEJLUPKOVÁ*

The Bible is an all-embracing tapestry, weaving together the nature and purposes of God, its strands relating how he creates, saves, and blesses. It is brim-filled with great names; lives glorious or tragic; exciting plots and impressive outcomes. Yet, as ordinary individuals, we should not be overwhelmed by the immensity of the biblical stories revealing how God works in our world. The scriptures do not demand us to live out a doctrinal system, a moral or religious code as depicted by its contents. Rather, they invite us to understand what it looks like to be human and what is needed for us to enter and mature as human beings in our stories where God is the pivotal theme. In studying biblical stories and characters, we can indeed glimpse how we should or should not live our lives. But, even more, we see how in fact we do live, how our everyday experiences are the very building blocks that God uses to work out his purposes of salvation in us and in the world.

The story of Abigail dramatically compares the character and temperament of a gracious, discerning woman with that of her surly, bigoted husband Nabal. Abigail deflected the blame for a tense state of conflict between Nabal and David, away from her husband to herself,

and, in so doing, brought calm to a situation that had had the potential of becoming a massacre of innocent people. Further, her actions not only appeased David's anger, but stopped him from taking revenge with his own hands.

## Setting the Scene

### Historical background

God had personally governed his people Israel for centuries. Throughout this theocratic rule, God used his anointed leaders to govern his people, the last leaders being called judges. Samuel was the last of the judges, and he also functioned as a prophet. The people had a leader they could trust, a leader of integrity, one on whom they could rely. However, despite Samuel's leading the people closer to God and the nation's growing in its trust of his leadership, Israel longed for a king like the nations around her. Samuel was disappointed with their request, so he brought it before the Lord. After reassuring Samuel that Israel's call for a king represented a crisis of confidence in God himself rather than their lack of trust and confidence in Samuel, God allowed the people to have their way. Through Samuel, God decided that Saul would fulfill the role, and so Saul was acclaimed by the people as their first earthly king.

In 1050 B.C., Saul began his reign as king with national trust at its highest level, the result of Samuel's faithful work rather than the effect of Saul being the new king. Samuel's decision to merge a ceremony of covenant renewal with the formal installation of Saul as king established the king as an instrument of God's covenantal rule of Israel; the king did not govern in his own right, but under the authority of God. The king only exercised authority legitimately while he remained obedient to God. However, Saul showed his true colors and made three major mistakes in which he refused to obey Samuel, subsequently leading to God's rejection of him as king. God was grieved that he had made Saul king over Israel and, again through Samuel, chose the young David to succeed him.

After being rejected by God, Saul became increasingly subject to periods of depression that sometimes verged on madness. Ironically,

David the musician was appointed to provide comfort for Saul's melancholy, and so their lives became intertwined. After David became a national hero by killing the Philistine Goliath, Saul became jealous of him and tried to kill him. David had no choice but to become an outlaw, supported by a band of fugitives who lived on the margins of Israelite society. So David knew that Saul was an irrational ruler whose days were numbered. He knew that he himself was to become king. As the story of Abigail unfolds, David had been living as an outlaw in the desert, surrounded by his six hundred fugitive men whom he had turned into a fighting force, constantly pursued by Saul's men for the last eleven or twelve years. Despite Saul's murderous attempts on his life, David had proved himself loyal and faithful to his king, refusing to retaliate.

**Social and economic background**

David and his men acted as a type of vigilante force, protecting the flocks of wealthy livestock owners from raiders and wild animals. The custom was that when the sheep were sheared, these "security guards" would be paid a gratuity, a thank-you for their protection. Sheep, and the more common goats, were a major feature of ancient Israel's rural economy, being used for food, fabric, within the sacrificial system, as a method of payment and as a measure of wealth. Tents were made with fabric spun from goat hair, as were the curtains of the tabernacle. Sheep were used in striking bargains and were also a measure of God's blessing on the owner. Annually, in springtime, the sheep would be sheared, cutting off the whole woolen coat of the animal. The lanolin contained in the fleece would be removed as a sweet-smelling, softening, thick oil used in cleansing and beauty treatments. The fleece would then be spun to make woolen clothes.

**Time and location**

1 Samuel 25 opens with the statement that Samuel died and all Israel assembled and mourned for him, burying him at his home in Ramah, some five or six kilometers northeast of Jerusalem. David

then moved into the desert of Maon,[1] about forty kilometers south of Jerusalem and just south of Carmel.

**The characters**

We have already noted the character of Israel's king-elect, David. He was in a very difficult position, being hounded by Saul who had already made many attempts on his life, banished to living in the wilderness with his band of renegades, yet knowing from Samuel that he was chosen by God to become heir to the throne. When an amazing opportunity presented itself, he had shown great restraint and understanding of God's law when he had not taken revenge on Saul.[2]

Nabal—the very name meant "Fool," and folly went with this man.[3] Folly is a lack of wisdom or contempt for wisdom, which shows itself in a lack of understanding and obedience. Scripture contrasts human foolishness with divine wisdom. Human folly is seen in rebellion against God, ignoring his way and will, a failure to understand him, encompassing moral and/or spiritual irresponsibility. Nabal was "surly and mean in his dealings."[4] His servant described him as "such a wicked man that no one can talk to him," a man who hurled insults at David's messengers as they offered him their master's greetings.[5] He was disrespectful, stingy and miserly, belligerent, obstinate, arrogant, ill-mannered, and rude. His reluctance to part with his money or possessions was foolishness indeed and, like all miserliness, led to misery.

He "was very wealthy. He had a thousand goats and three thousand sheep."[6] Ungodly people often make the possession of wealth a priority. They do not understand the true nature of wealth, and they do not realize that they will have to face God in judgment. The ungodly grow rich, often obtaining their riches unjustly, accumulating, hoarding, and trusting in their riches. However, the ungodly, like all people, must

---

[1] 1 Sam 25:1.
[2] 1 Sam 24.
[3] 1 Sam 25:25.
[4] 1 Sam 25:3.
[5] 1 Sam 25:15, 17.
[6] 1 Sam 25:2.

leave their riches to others. Lastly, Nabal was a drunk and a glutton.[7] His excessive eating and drinking represented greed, the unrestrained self-indulgence that often leads to a deeper iniquity, and represents a rejection of godly moderation.

Abigail was the antithesis of her husband. She was beautiful both physically and spiritually, bringing pleasure to those who beheld her. She was intelligent,[8] using her human cleverness to the full in God's service and to dedicating her gifts and abilities to him. She was wise and prudent, sensitive and sensible, generous and hospitable.

Outward appearance, that which is visible externally, may reveal the true person, but often it misleads instead. Here, both Nabal and Abigail had outward appearances that reflected their real characters.

### David, Nabal, and Abigail

During the winter months, in the desert of Maon, David and his men had been safeguarding the flocks of Nabal. It was now springtime. On hearing that Nabal was shearing sheep in Carmel, David sent ten of his young men to greet Nabal and ask for the gratuity payment due to them in respect of their protection of his animals and shepherds. They were to suggest to Nabal that he could check with his own servants as to their worth in doing this work and, since sheep-shearing was a festive time, to ask him to give them and their master David whatever he could find for them.

David's men showed grace in their manner of approach to Nabal, and naturally expected grace in return—grace expressed as generosity and kindness. They waited. Instead they were met with insults, prejudice, contempt, and indifference. Nabal answered, "Who is this David? Who is this son of Jesse? Many servants are breaking away from their masters these days. Why should I take my bread and water, and the meat I have slaughtered for my shearers, and give it to men coming from who knows where?"[9] In biblical times, meat was a luxury, eaten at special times such as this festival of sheep-shearing.

---

[7]1 Sam 25:36.

[8]1 Sam 25:3.

[9]1 Sam 25:10–11.

Likewise, this was desert country, so water was also very precious. Nabal was certainly not going to share any hospitality with these rogues!

The ten young men turned round and went back to report every word to their master. David was furious. He commanded four hundred of his men to put on their swords, armed himself likewise, and, leaving two hundred men to stay with their supplies, set out.

Meanwhile, one of Nabal's shepherds told Abigail, Nabal's wife, what had happened. He related how David had sent his messengers to salute Nabal, but that the wealthy owner had responded by tearing into them with insults. The shepherd confirmed that David's men had protected them very well during the previous months, but, unless his mistress could do something quickly, disaster would befall them since nobody could reason with her impossible husband.

Using her intelligence and great discernment, Abigail had to think of a way to bring calm to this tense situation, a way that would appease David whilst protecting Nabal. Acknowledging David as God's anointed, she knew that his anger should be defused and he should be discouraged from carrying out revenge with his own hands. Further, she appreciated that she had to leave room for God to move in his time and in his way in her husband's life. However, Abigail recognized that her conduct must ultimately honor the Lord. She flew into action. She had a feast of bread, wine, mutton (sheep meat), roasted grain, raisin cakes, and fig cakes loaded on to some donkeys, asked her servants to go on ahead of her, and followed on her donkey. She said nothing to Nabal.

As Abigail followed the feast fit for a king, her donkey descending into a ravine, David and his men were descending into the same ravine from the opposite direction. David had just been talking with his men, bemoaning the fact that all his efforts to protect Nabal's property in the desert had been useless, had been rewarded with nothing but insults, his good being repaid with evil. He vowed to destroy every male in Nabal's household by the morning. He was out for revenge. Like Nabal, he was demonstrating folly by ignoring God's command, "Do not seek revenge or bear a grudge against one of your people, but

love your neighbor as yourself."[10] He was stooping to the depths of a Pharaoh of a previous era.[11]

Abigail and David met there on the road. Abigail quickly dismounted and fell on her knees at his feet, her face to the ground in homage, a gesture of reverence, honor, and submission before a future king appointed by God. "My lord, let me take the blame!"[12] What a gentle and sensitive spirit! Of course her husband deserved everything that was coming to him, but Abigail was prepared to shoulder the responsibility for the grave situation. She was not concerned about her own safety and reputation, but was willing to sacrifice herself to protect her husband and the innocent family members whose lives were in such danger. She was also thinking about David's future.

"Please let me speak to you. Listen to what your servant has to say. Don't dwell on what that brute Nabal did. He acts out his name: Nabal, fool—and foolishness oozes from him. I wasn't there when the young men my master sent arrived. I didn't see them. And now, my master, as God lives and as you live, God has kept you from this avenging murder—and may your enemies, all who seek my master's harm, end up like Nabal! Now take this gift that I your servant girl, have brought to my master, and give it to the young men who follow in the steps of my master.

"Forgive my presumption! But God is at work in my master, developing a rule solid and dependable. My master fights God's battles! As long as you live no evil will stick to you.

> If anyone stands in your way,
>     if anyone tries to get you out of the way,
> Know this: Your God-honored life is tightly bound
>     in the bundle of God-protected life;
> But the lives of your enemies will be hurled aside
>     as a stone is thrown from a sling.

"When God completes all the goodness he has promised my master and sets you up as prince over Israel, my master will not have

---

[10] Lev 19:18.

[11] Ex 7–11.

[12] 1 Sam 25:24a.

this dead weight in his heart, the guilt of an avenging murder. And when God has worked things for good for my master, remember me."[13]

Abigail was seeking David's forgiveness for her audacity in approaching him and speaking to him in this way. She was admitting negligence for not being around, for not offering hospitality when David's messengers had arrived. Likewise, she was apologizing for her husband's appalling behavior. Far more imperative, however, was her recognition of David as God's appointed servant and future leader of Israel, a man who fought God's battles. She was declaring the urgency of averting his desire for revenge, the potential guilt of which would have been "on his conscience" as a "staggering burden of needless bloodshed or of having avenged himself."[14] With careful discernment, avoiding rash behavior or speech, and showing tact and wisdom in her relationship with David, Abigail's prudence had averted disaster. A lowly "servant," she had counseled a future king!

David responded by praising God for having sent Abigail to intervene. He asked the Lord to bless her for her good judgment and for keeping him from becoming guilty of bloodshed or of avenging himself, rather than leaving revenge to the Lord. He then accepted the gifts she had brought on the donkeys, telling her to return home in peace. He had acknowledged her words and promised to grant her request.

When Abigail reached home, Nabal was holding his own "king's banquet" and was very drunk. She deferred telling him what she had done until he had sobered up in the morning. On hearing the whole story, he had a heart attack and fell into a coma. Some ten days later, he died. David, learning of Nabal's demise, again praised the Lord, this time for upholding his cause against Nabal, for keeping him from an evil act, and for bringing Nabal's wrongdoing down on his own head. He then sent his servants to Abigail in Carmel, telling her that David had sent them to take her to become his wife. Still true to character, Abigail bowed down to them, with her face to the ground, saying she was ready to serve them and wash their feet—expressing,

---

[13]1 Sam 25:24b–31 from *The Message*, by E. H. Peterson.

[14]1 Sam 25:31.

once more, hospitality and servanthood. She quickly mounted a donkey and, attended by her five maids, went with the messengers and became David's wife.

## Reflections

This short, concise saga of human behavior in the face of crisis offers us profound models of godly and ungodly characteristics. We should not, however, attempt to mold ourselves to fit the godly virtues, to "think like this in order to live well." Rather we must read in it the very humanness of the characters, their strengths and weaknesses, their relationships to each other and, ultimately, their relationship with God. And then we can begin to perceive ourselves, our own humanity. Human life, other than mere biology, must deal with God. We need to constantly and prayerfully ask ourselves, "Where does God fit into this? Is he central, or have I placed him on the periphery, or have I omitted him altogether?"

Undoubtedly, Abigail was a noble and virtuous woman, comparable to the later "wife of noble character."[15] She had God at the center of her life: He was her Lord, her King, and her Master. Her thinking and her actions revolved around God. She was sensitive, having deep feelings for others and sympathy for their needs, leading to appropriate action on their behalf.

David also was sensitive, though here he was oversensitive to Nabal's rejection, and this led to his hasty reaction of seeking revenge. It is interesting to consider why David should react in this way in this story, when he had previously chosen not to take revenge against Saul,[16] and would again spare Saul's life in a subsequent encounter.[17] Why was God a central consideration when David was dealing with Saul, but was somehow missing from the equation when it came to Nabal? Could it have been because of the difference in status of the two men? In the situation with Nabal, in his haste did he forget God's commandment?

---

[15]Prov 31:10–31.

[16]1 Sam 24.

[17]1 Sam 26.

It is mine to avenge; I will repay.
    In due time their foot will slip;
their day of disaster is near
    and their doom rushes upon them.[18]

Whatever the reason, David's reaction to Nabal's insults was to take revenge—to kill him and all the male members of his household before the next dawn. How often do we do that, flare up in anger, seeking retaliation against someone for some offense, getting the situation out of all proportion? Yet, if God is truly at the center of our lives, he will answer our prayer: "And lead us not into temptation, but deliver us from the evil one."[19] He will use other people, events, or situations to stop us sinning. He used Abigail to stop David.

As we study the characters in this and other Bible stories, may we prayerfully ask the Holy Spirit to work in us a desire for such godly characteristics as displayed by Abigail: generosity, hospitality, prudence, virtue, patience, wisdom, sensitivity, discernment, and peacemaking. May we ask for these in the words of James: "If any of you lacks wisdom, he should ask God, who gives generously to all without finding fault, and it will be given to him. But when he asks, he must believe and not doubt."[20]

---

[18]Deut 32:35.
[19]Matt 6:13.
[20]Jas 1:5–6a.

សំណុំនិកឃ្ញុំ ៥/១ (តុលា ២០០៤): ១១៣-២៩



# អេប៊ីកែល អ្នកចងស្ពានមេត្រី

*អ្នកស្រី លីនដា វេលូបកូវ៉ា*

ព្រះគម្ពីរគឺជាគ្រឿងប៉ាក់ដែលត្បាញបញ្ចូលគ្នានូវនិស្ស័យលក្ខណៈ និង គោលបំណងរបស់ព្រះជាម្ចាស់ការនោះគឺបង្ហាញអំពីការបង្កបង្កើតការសង្គ្រោះ និង ការប្រទានព្រះពរផ្សេងៗរបស់ព្រះជាម្ចាស់ ។ ព្រះគម្ពីរមានពេញទៅដោយឈ្មោះដ៏អស្ចារ្យជាច្រើន អ្នកមានជីវិតរស់នៅដោយភាពរុងរឿង ឬ រស់នៅក្នុងភាពខ្លោចផ្សាលាយឡំនឹងផែនការសំងាត់ដ៏រំភើប និង ការជាប់ចិត្តទៅលើលទ្ធផលនៃការប្រព្រឹត្តិទាំងឡាយ ។ ទោះបីយ៉ាងនោះក៏ដោយក្នុងឋានៈយើងជាបុគ្គលធម្មតា យើងមិនត្រូវមានការរំភើបខ្លាំងពេក ដោយសាររឿងនៅក្នុងព្រះគម្ពីរដែលមានភាពធំមហិមាដែលបើកសំដែងពីរបៀបដែលព្រះជាម្ចាស់ធ្វើការនៅក្នុងលោកនេះ។ ព្រះគម្ពីរមិនបានបញ្ជាយើងឲ្យរស់នៅក្រៅប្រព័ន្ធគោលលិទ្ធិសីលធម៌ ឬ របៀបរបបសាសនាដូចដែលបានបរិយាយនៅក្នុងមាតិការបស់ព្រះគម្ពីរនោះទេ ។ ប៉ុន្តែប្រាប់យើងឲ្យយល់អំពីថាតើធ្វើជាមនុស្សមានសភាពយ៉ាងណា តើអ្វីទៅដែលជាសេចក្តីត្រូវការរបស់យើងដើម្បីឲ្យ

អាចចូលក្នុងលក្ខណៈ និងមានសភាពពេញវ័យជាមនុស្សភាពនៅក្នុងរឿងរបស់យើងដែលព្រះជាម្ចាស់ជាផ្នែរឿងដ៏សំខាន់ ។ នៅក្នុងការសិក្សារឿងទាំងឡាយ និងលក្ខណៈសម្បត្តិនៅក្នុងព្រះគម្ពីរនោះយើងពិតជាអាចមើលត្រួសៗពីរបៀបនៃជីវិតដែលយើងគួររស់នៅ និង មិនគួររស់នៅបែបណានោះ ។ ប៉ុន្តែជាងនោះទៅទៀតយើងឃើញការពិត នៃរបៀបដែលយើងរស់នៅ បទពិសោធន៍នៃជីវិតរស់នៅប្រចាំថ្ងៃរបស់យើង គឺជាផ្នែកដ៏សំខាន់ដែលព្រះជាម្ចាស់ប្រើដើម្បីធ្វើការសម្រេចពីគោលដៅនៃការសង្គ្រោះរបស់ព្រះអង្គ ដែលមាននៅក្នុងជីវិតយើង និងនៅក្នុងពិភពលោកយើងនេះ ។

រឿងរបស់អ័ប៊ីកែលជាការប្រៀបធៀបពីលក្ខណៈសម្បត្តិ និង ការមានអធ្យាស្រ័យល្អ និងមានអំណោយទានយល់ដឹងសភាពការណ៍ចេះសង្កេតរបស់ស្ត្រីម្នាក់ដែលពិតជាស្ត្រីដែលជាជំនួយដ៏ប្រសើរដល់ប្តី ឈ្មោះណាបាល ដែលមានភាពគម្រិះគម្រុះគិតថាខ្លួនគ្រាន់បើ ។ អ័ប៊ីកែលបានបង្វែរភ្លើងជម្លោះដែលមានភាពតានតឹងយ៉ាងខ្លាំងរវាងណាបាល និង ដាវីឌ គឺបានបង្វែរចេញពីប្តីរបស់ខ្លួន ហើយទទួលកំហុសនោះទៅដាក់លើខ្លួនឯង តាមរយៈការនេះ ហើយដែលធ្វើឲ្យហេតុការណ៍មានសភាព ស្ងប់ស្ងាត់ទៅវិញ គេចផុតពីការកាប់សម្លាប់យ៉ាងសាហាវដែលអាចកើត មានឡើងដល់មនុស្សដែល មិនដឹងអីនោះ នៅក្នុងផ្ទះរបស់ណាបាលទាំងមូល ។ ជាងនោះទៅទៀតសកម្មភាព របស់នាង មិនមែនគ្រាន់តែរំលត់ កំហឹងរបស់ដាវីឌប៉ុណ្ណោះទេ ប៉ុន្តែអាចបញ្ឈប់គាត់ចេញពីការសងសឹក ដោយផ្ទាល់ដៃរបស់គាត់ទៀតផង ។

## ការរៀបចំឆាក

### សាវតារប្រវត្តិសាស្ត្រ

ព្រះជាម្ចាស់គ្រប់គ្រងរាស្ត្រអ៊ីស្រាអែល គឺជារាស្ត្ររបស់ព្រះអង្គដោយផ្ទាល់ជាច្រើនសតវត្សរ៍កន្លងមកហើយ ។ តាមរយៈការគ្រប់គ្រងតាមបែប

ទេវាធិប្បតេយ្យព្រះជាម្ចាស់ប្រើអ្នកដឹកនាំដែលព្រះអង្គបានចាក់ប្រេងតាំងដើម្បីឲ្យគ្រប់គ្រងដល់រាស្ត្ររបស់ព្រះអង្គអ្នកដឹកនាំចុងក្រោយគេដែលគេបានហៅថាពួកចៅហ្វាយ ។ សាំយូអែលជាអ្នកចុងក្រោយក្នុង ចំណោមពួកចៅហ្វាយហើយមានតួនាទីជាហោរាផងដែរ ។ ពួកបណ្តាជនមានអ្នកដឹកនាំដែលពួកគេអាចទុកចិត្តបានជាអ្នកដឹកនាំដែលសុចរិតជាមនុស្សដែលគេអាចពឹងពាក់បាន ។ ទោះបីយ៉ាងណាក៏ដោយថ្វីបើ សាំយូអែលដឹកនាំមនុស្សចូលទៅកៀកនឹងព្រះជាម្ចាស់ និង ប្រជាជាតិមានការរីកចំរើនក្នុងការទុកចិត្តទៅលើអ្នកដឹកនាំរបស់ខ្លួនកាន់តែខ្លាំងឡើង តែជនជាតិអ៊ីស្រាអែល បែរជាទាមទារឲ្យមានស្តេចដូចជាប្រជាជាតិដែលនៅជុំវិញខ្លួនទៅវិញ ។ សាំយូអែលមានការអស់សង្ឃឹមចំពោះសេចក្តីសំណូមរបស់គេ ដូច្នេះគាត់ក៏នាំរឿងនេះទៅទូលដល់ព្រះជាម្ចាស់ ។ បន្ទាប់ពីព្រះជាម្ចាស់បានបញ្ជាក់អះអាងដល់សាំយូអែលថា ការដែលអ៊ីស្រាអែលអំពាវនាវចង់បានស្តេចនោះ គឺតំណាងឲ្យវិបត្តិនៃការមិនទុកចិត្តដល់ព្រះជាម្ចាស់ផ្ទាល់ជាជាងការខ្វះការទុកចិត្តទៅលើសាំយូអែល ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យពួកគេធ្វើតាមចិត្តរបស់ពួកគេ ។ តាមរយៈសាំយូអែលព្រះជាម្ចាស់បានសម្រេចព្រះហឫទ័យថាសូលអាចបំពេញនូវតួនាទីនេះ ដូច្នេះហើយបណ្តាជនបានប្រកាសទទួលយកសូលធ្វើជាស្តេចទីមួយនៅលើផែនដី ។

នៅក្នុងឆ្នាំ ១០៥០ មុនគ្រីស្តសករាជស្តេចសូលចាប់ផ្តើមសោយរាជ្យជាស្តេចដោយមានការទុកចិត្តពីប្រជាជាតិ ក្នុងកំរិតមួយយ៉ាងខ្ពស់បំផុតលទ្ធផលនៃការងារស្មោះត្រង់របស់សាំយូអែលនោះ គឺប្រសើរជាងស្តេចសូលដែលបានក្លាយស្តេចថ្មីនោះទៅទៀត ។ ការសំរេចចិត្តរបស់ សាំយូអែល ដើម្បីដាក់ពិធីតាំងសញ្ញាឡើងវិញបញ្ចូលគ្នាជាមួយការតែងតាំងស្តេចសូលជាផ្លូវការទុកជាផ្នែកមួយរបស់ព្រះជាម្ចាស់ដែលព្រះអង្គ ប្រើដើម្បីគ្រប់គ្រងលើរាស្ត្រអ៊ីស្រាអែល គឺស្តេចមិនមែនគ្រប់គ្រងប្រជារាស្ត្រដោយសិទ្ធិអំណាចផ្ទាល់ខ្លួនឡើយ ប៉ុន្តែដឹកនាំដោយស្ថិតនៅក្រោមអំណាចរបស់ព្រះជាម្ចាស់ ។

ស្តេចអាចអនុវត្តសិទ្ធិអំណាចដោយស្របច្បាប់បាននោះ លុះត្រាណាស្តេចស្ថិតនៅក្រោមការស្តាប់បង្គាប់ដល់ ព្រះជាម្ចាស់ ។ ទោះបីយ៉ាងណាក៏ដោយ ស្តេចសូលបានបង្ហាញពីពណ៌សម្បុរពិតរបស់ខ្លួន និង បានប្រព្រឹត្តកំហុសឆ្គងបីយ៉ាងសំខាន់ៗដែលទ្រង់បានបដិសេធន៍មិនព្រមស្តាប់បង្គាប់ដល់ សាំយូអែលដែលជាហេតុនាំឲ្យព្រះជាម្ចាស់បដិសេធន៍មិនទទួលសូលជាស្តេចតទៅទៀត ។ ព្រះជាម្ចាស់មានការសោកស្តាយយ៉ាងខ្លាំង ដែលព្រះអង្គបានតែងតាំងឲ្យសូលធ្វើជាស្តេចនៃរាស្ត្រអ៊ីស្រាអែល ហើយតាមរយៈសាំយូអែលម្តងទៀត ព្រះជាម្ចាស់បានជ្រើសរើសក្មេងដាវីឌឲ្យធ្វើជាស្តេចជំនួសបន្ទាប់ពីស្តេចសូល ។

បន្ទាប់ពីព្រះជាម្ចាស់លែងទទួលស្គាល់ស្តេចសូលជាស្តេចតទៅទៀតនោះ សូលចាប់ផ្តើមមានការតប់ប្រមល់យ៉ាងខ្លាំង រហូតដល់ពេលខ្លះមានកំហឹងឆេះឆួលយ៉ាងខ្លាំង ។ ដោយសារមានភាពតានតឹងបែបនោះ ហើយទើបគេបានចាត់តាំងឲ្យដាវីឌដែលជាតន្ត្រីករម្នាក់ មកលេងភ្លេង ដើម្បីកំសាន្តចិត្តដល់ភាពសោកសៅរបស់ស្តេចសូល ដោយព្រោះហេតុ ដូច្នេះហើយ ជីវិតរបស់គេទាំងពីរបានវេញបញ្ចូលគ្នាយ៉ាងស្និតស្នាល ។ បន្ទាប់ពីស្តេចដាវីឌក្លាយទៅជាវីរៈបុរសជាតិ ពេលដែលគាត់បានសម្លាប់ កូលីយ៉ាតជាសាសន៍ភីលីស្ទីនរួចមកស្តេចសូលចាប់ផ្តើមច្រណែនដាវីឌ ហើយមានបំណងចង់សម្លាប់ដាវីឌចោល ។ ដាវីឌគ្មានជម្រើសឡើយ គឺ ក្លាយទៅជាជនរស់នៅក្រៅច្បាប់ដែលមានការជួយគាំទ្រពីមនុស្សមួយក្រុមដែលរស់នៅក្នុងសហគមន៍ អ៊ីស្រាអែលគេមិនសូវរាប់រក ។ ដូច្នេះ ដាវីឌដឹងថាស្តេចសូលជាអ្នកគ្រប់គ្រងដែលគ្មានការពិចារណា ហើយរង់ចាំតែថ្ងៃធ្លាក់ពីអំណាចនោះ ។ គាត់បានដឹងយ៉ាងច្បាស់ថាខ្លួនគាត់ថ្ងៃមួយ នឹងក្លាយទៅជាស្តេចម្តង ។ ដូចដែលរឿងរបស់អ័ប៊ីកែលត្រូវបានលាតត្រដាងឡើងឲ្យយើងបានដឹង ដាវីឌបានរស់នៅជាជនក្រៅច្បាប់នៅឯវាលរហោស្ថានដែលមានមនុស្សស្មោះត្រង់នៅជុំវិញគាត់ចំនួន៦០០នាក់ ហើយអ្នកទាំងនោះក្រោយមកក្លាយជាអ្នកប្រយុទ្ធដ៏ស្និតស្នាញដោយសារតែមានការដេញ

តាមពីសំណាក់ទាហានរបស់ស្តេចសូលឥតឈប់ជាបន្តបន្ទាប់នៅក្នុងរយៈពេល ១១ ឬ ១២ ឆ្នាំចុងក្រោយនេះ ។ យ៉ាងណាមិញស្តេចសូលបានប៉ុនប៉ងធ្វើឃាតលើជីវិតដាវីដជាច្រើនលើកច្រើនសា ដាវីឌនៅតែបង្ហាញពីខ្លួនឯងថាស្មោះត្រង់នៅចំពោះស្តេចរបស់ខ្លួនជានិច្ចដោយមិនបានឆក់យកឱកាសសងសឹកអ្វីឡើយ ។

## ប្រវត្តិសាវតារនៃសង្គម និងសេដ្ឋកិច្ច

ដាវីឌនិងពួកទាហានរបស់គាត់ដើរតួជាអ្នកឃាមល្បាតដោយប្រុងប្រយ័ត្នការពារហ្វូងចៀមរបស់បុរសម្នាក់ដ៏មានស្តុកស្តម្ភកុំឲ្យមានចោរព្រៃមកឆក់ប្លន់ និង សត្វសាហាវផ្សេងៗមកបំផ្លាញបានឡើយ ។ តាមទំនៀមទំលាប់នៅពេលដែលគេកាត់រោមចៀមម្តងៗ ត្រូវគេត្រូវបង់ថ្លៃការពារឲ្យអ្នកការពារដើម្បីសម្តែងនូវការអរគុណចំពោះ " អ្នកការពារ " ចៀមទាំងនេះ ។ សត្វចៀម និង សត្វពពែគឺជាពពួកសត្វដ៏សាមញ្ញដែលជាសេដ្ឋកិច្ចសំខាន់របស់ពួកអ្នកដែលរស់នៅជនបទនៃប្រទេសអ៊ីស្រាអែលពីបុរាណ គឺពួកគេប្រើសត្វទាំងនោះសំរាប់ធ្វើជាអាហារ ធ្វើជាសរសៃអំបោះសំរាប់ត្បាញ ធ្វើអាវពាក់ប្រើនៅក្នុងប្រព័ន្ធនៃការធ្វើយញ្ញបូជាទុកប្រើក្នុងរូបមន្តនៃការចំណាយនៃការជួញដូរផ្សេងៗ និងប្រើជារង្វាស់នៃការវាស់ពីទ្រព្យសម្បត្តិរបស់មនុស្សថាអ្នកនោះមាន ឬ ក្រ ដោយសារមានសត្វទាំងនោះច្រើនឬតិច ។ សំពត់តង់សម័យនោះគេបានធ្វើឡើងដោយត្បាយចេញពីរោមពពែដូចជា វាំងននដែលគេប្រើនៅក្នុងរោងឧបោសថក៏គេត្បាញពីរោមចៀមដែរ ។ ចៀមត្រូវបានប្រើនៅក្នុងការតថ្លៃចំពោះការដេញថ្លៃអ្វីមួយ ហើយក៏គេប្រើជារង្វាស់នៃព្រះពរដែលព្រះជាម្ចាស់បានផ្តល់ឲ្យម្ចាស់វាដែរ ។ ជារៀងរាល់ឆ្នាំនៅក្នុងនិទាឃរដូវចៀមត្រូវបានកាត់រោមកាត់រោមដែលនៅជុំវិញខ្លួនវាទាំងមូល ។ ជាតិខ្លាញ់ដែលមាននៅក្នុងរោមចៀមត្រូវបានគេយកចេញយ៉ាងស្អាត នៅពេលនោះរោមចៀមមានក្លិនឈ្ងុយគេបាន

ធ្វើឲ្យមាន ភាពស្រទន់ខ្លាញ់ដែលខាប់គេប្រើសំរាប់សំអាត និង ធ្វើរោមចៀមមានសោភ័ណភាពយ៉ាងល្អ ។ បន្ទាប់មករោមចៀមត្រូវបានគេយកទៅរវៃបង្កើតជាក្រណាត់ ។

**ពេលវេលា និងទីកន្លែង**

១សាំយូអែល២៥ ចាប់ផ្ដើមឡើងដោយសេចក្ដីថ្លែងអំពីការស្លាប់របស់សាំយូអែលហើយជនជាតិអ៊ីស្រាអែលទាំងអស់មកប្រមូលផ្ដុំគ្នានិងបានកាន់ទុក្ខចំពោះសពរបស់គាត់ ដែលគេបានបញ្ចុះនៅក្នុងរ៉ាម៉ាជាស្រុកកំណើតរបស់គាត់ ដែលមានចំងាយប្រហែល៥ ឬ ៦ គីឡូម៉ែត្រផ្នែកខាងជើងប៉ែកខាងកើតនៃក្រុងយេរូសាឡឹម ។ បន្ទាប់មកដាវីឌចេញទៅក្នុងវាលរហោស្ថានម៉ាអូន[១] ប្រហែលជា ៤០ គីឡូម៉ែតខាងត្បូងនៃក្រុងយេរូសាឡឹម និង ខាងត្បូងនៃកើមែល។

**លក្ខណៈសម្បត្តិ**

យើងបានកត់សំគាល់ហើយអំពីលក្ខណៈសម្បត្តិរបស់ស្ដេចនៃប្រទេសអ៊ីស្រាអែលគឺព្រះបាទដាវីឌដែលត្រូវបានជ្រើសរើសឲ្យមកធ្វើជាស្ដេច ។ ព្រះបាទដាវីឌស្ថិតនៅក្នុងមុខតំណែងដ៏ពិបាកបំផុត ដោយសារស្ដេចសូលបានប៉ុនប៉ងប្រហារជីវិតរបស់ទ្រង់ជាច្រើនដងមកហើយដែលត្រូវនិរទេសរត់គេចទៅរស់នៅវាលរហោស្ថាន ជាមួយក្រុមរបស់គាត់តែទ្រង់ក៏បានដឹងដែរ តាមរយៈហោរាសាំយូអែលថាទ្រង់គឺជាម្នាក់ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យក្លាយទៅជាអ្នកស្នងក្នុងរាជបល្ល័ង្ក ។ នៅពេលដែលឱកាសដ៏អស្ចារ្យផ្ដល់មកឲ្យទ្រង់នោះ ទ្រង់បានបង្ហាញជំហរយ៉ាងអស្ចារ្យ និង ការយល់

---

[១] *១សាំយូអែល ២៥:១*

ដឹងពីក្រឹត្យវិន័យរបស់ព្រះជាម្ចាស់គឺទ្រង់មិនបានផ្ញៀតឱកាសសងសឹកដល់ស្តេចសូលឡើយ [២]។

ណាបាល ឈ្មោះនេះមានន័យថា " ចំកួតហើយអ្នកចំកួតទៅជាមួយគាត់ដែរ "[៣]។ ចំកួតគឺជាការខ្វះប្រាជ្ញា ឬការមើលងាយប្រាជ្ញាដែលបង្ហាញពីការខ្វះការយល់ដឹងនិងការស្តាប់បង្គាប់ ។ បទគម្ពីរបង្ហាញពីភាពចំកួត របស់មនុស្សតាមរយៈការទាស់ប្រឆាំងទៅនឹងព្រះជាម្ចាស់ ។ អំពើចំកួតរបស់មនុស្សបង្ហាញឲ្យឃើញការបះបោរប្រឆាំងនិងព្រះជាម្ចាស់មិនអើពើចំពោះផ្លូវរបស់ព្រះជាម្ចាស់ និង បំណងព្រះហឫទ័យរបស់ព្រះអង្គ គឺបរាជ័យក្នុងការស្វែងយល់អំពីព្រះអង្គមិនមានការទទួលខុសត្រូវទាំងខាងផ្នែកសីលធម៌និងខាងវិញ្ញាណ ។ ណាបាល " ពិតជាប្រព្រឹត្តនូវអំពើកម្រិះកម្រុះ និង កាច "[៤]។ អ្នកបំរើរបស់គាត់បានពិពណ៌នាអំពីគាត់ថា " ជាមនុស្សអាក្រក់ដែលគ្មានមនុស្សណាម្នាក់អាចនិយាយរកគាត់បានទេ" ជាមនុស្សដែលប្រមាថដល់អ្នកនាំសាររបស់ដាវីឌ នៅពេលដែលពួកគេជូនពាក្យជំរាបសួររបស់ចៅហ្វាយពួកគេ [៥]។ គាត់ជាមនុស្សដែលខ្វះការ គោរព កំណាញ់ និងទុរគត៌ ល្មោភសង្គ្រាម ចចេស ក្រអឺតក្រអោង ចរិតអាក្រក់ ច្រងេងច្រងាង ។ ការស្ទាក់ស្ទើរក្នុងការចែករំលែកលុយកាក់ ឬទ្រព្យសម្បត្តិរបស់គាត់នោះគឺជាអំពើឆ្កួតល្ងីល្ងើបំផុត ហើយភាពកំណាញ់ទាំងអស់នោះនាំគាត់ទៅរកការឈឺចាប់ ។

គាត់ " ជាមនុស្សដែលមានស្តុកស្តម្ភ ។ គាត់មានពពែមួយពាន់ និងចៀមបីពាន់ "[៦]។ មនុស្សដែលមិនកោតខ្លាចព្រះគេតែងតែយកទ្រព្យសម្បត្តិ

---

[២] ១សាំយូអែល ២៤

[៣] ១សាំយូអែល ២៥:២៥

[៤] ១សាំយូអែល ២៥:៣

[៥] ១សាំយូអែល ២៥:១៥ ; ១៧

[៦] ១សាំយូអែល ២៥:២

របស់គេធ្វើជាអាទិភាពនៃជីវិតរបស់គេ ។ ពួកគេមិនបានដឹងពីភាពពិតនៃទ្រព្យសម្បត្តិនោះទេហើយពួកគេក៏មិនបានដឹងថាថ្ងៃមួយពួកគេនឹងទៅជួបព្រះជាម្ចាស់នៅក្នុងសេចក្ដីជំនុំជំរះ ។ អ្នកដែលមិនកោតខ្លាចព្រះ ក្លាយជាអ្នកមានហើយតែងតែប្រមូលទ្រព្យសម្បត្តិរបស់ខ្លួនមកដោយ អំពើអយុត្តិធម៌ និង កាន់តែរីកចំរើនឡើងតំកល់ទុកទាំងចិត្តតែទៅលើទ្រព្យសម្បត្តិរបស់គេទៀតផង ។ ទោះបីយ៉ាងណាក៏ដោយដូចជាមនុស្ស ទាំងអស់ត្រូវតែលះបង់ទ្រព្យសម្បត្តិរបស់គេដល់អ្នកដទៃ ។ ចុងក្រោយ ណាបាលជាមនុស្សប្រមឹកនិងល្មោភស៊ី[៧]។ ការដែលស៊ី និង ផឹកហួសហេតុពេកតំណាងឲ្យភាពលោភលន់ ការបណ្ដែតបណ្ដោយខ្លួនដែលនាំទៅរកកំហុសយ៉ាងធ្ងន់ធ្ងរ និងជាតំណាងដល់ការបដិសេធន៍ភាពសមរម្យ ក្នុងនាមជាអ្នកកោតខ្លាចព្រះជាម្ចាស់ ។

អ័ប៊ីកែលគឺជាមនុស្សដែលមានភាពផ្ទុយពីប្ដីរបស់ខ្លួន ។ នាងមានភាពស្អាតស្អំទាំងខាងរាងកាយ និងខាងវិញ្ញាណនាំភាពត្រេកអរដល់អស់អ្នកដែលកត់សំគាល់សង្កេតមើលនាង ។ នាងជាមនុស្សដែលមានភាព វៃឆ្លាត[៨] ប្រើប្រាជ្ញាក្នុងភាពជាមនុស្សរបស់នាងដើម្បីបំពេញកិច្ចការព្រះហើយថ្វាយអំណោយទាន និង សមត្ថភាពរបស់នាងដល់ព្រះ ។ នាងជាមនុស្សដែលមានប្រាជ្ញា ហើយឆ្លាតរហ័សដឹងខ្លួន និងសមហេតុសមផលចិត្តល្អនិងរួសរាយរាក់ទាក់ ។

អ្វីដែលលេចឡើងនៅខាងក្រៅដែលយើងមើលឃើញផ្នែកនោះអាចបង្ហាញពីអត្តចរិកមនុស្សពិត ប៉ុន្តែជារឿយៗវាអាចនាំឲ្យយើងយល់ខុសទៅវិញ ។ នៅទីនេះណាបាល និង អ័ប៊ីកែលមានសភាពលេចឡើងនៅខាងក្រៅដែលឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិពិតប្រាកដរបស់ពួកគេ ។

---

[៧] *១សាំយូអែល ២៥:៣៦*

[៨] *១សាំយូអែល ២៥:៣*

## ដាវីឌ ណាបាល និងអប៊ីកែល

នៅសិសិររដូវ នៅឯវាលរហោស្ថានម៉ាអូន ដាវីឌ និងមនុស្សរបស់គាត់បានកំពុងថែររក្សាហ្វូងចៀមរបស់ណាបាល ។ ឥលូវនេះវាជារដូវស្លឹកឈើលាស់ ។ នៅពេលដែលឮថាណាបាលកំពុងកាត់រោមចៀមនៅ ឯកើមែល ដាវីឌបានបញ្ជូនមនុស្សកំលោះរបស់គាត់១០នាក់ឲ្យទៅជំរាបសួរណាបាល ហើយសូមប្រាក់ឧបត្ថម្ភខ្លះមកពីគាត់ដោយយល់ដល់ការដែលពួកគេ និង ដាវីឌ បានការពារហ្វូងសត្វ និង ចៀមរបស់គាត់ ។ ពួកគេបានប្រាប់ដល់ណាបាលថាគាត់អាចសួរតាមរយៈអ្នកបំរើរបស់ លោកអំពីតំលៃដែលពួកគេបានធ្វើការ ហើយដោយព្រោះការកាត់រោមចៀមគឺជាពេលវេលាបុណ្យត្រូវពេលសុំដើម្បីឲ្យលោកជួយពួកគេ និងចៅហ្វាយពួកគេ គឺដាវីឌ តាមការដែលលោកអាចជួយបាន ។

មនុស្សរបស់ដាវីឌបង្ហាញពីរបៀបសមរម្យក្នុងការទៅជួប ណាបាល ហើយជាធម្មតាតែងតែសង្ឃឹមចង់បាននូវភាពសមរម្យទាំងនោះមកវិញតាមរយៈចិត្តល្អនិងសប្បុរស ។ ពួកគេរង់ចាំយ៉ាងយូរ ។ តែផ្ទុយទៅវិញពួកគេជួបនូវការប្រមាថ ភាពប្រកាន់ការមើលងាយ និង ភាពព្រងើយកន្តើយ ។ ណាបាលបានឆ្លើយថា " តើដាវីឌជាអ្វី ? ហើយកូនអ៊ីសាយអ្វី ? សព្វថ្ងៃនេះមានបាវជាច្រើនដែលរត់ចោលពីចៅហ្វាយរបស់ខ្លួនទៅ ។ ដូច្នេះតើត្រូវឲ្យអញយកនំបុ័ងរបស់អញព្រមទាំងទឹក និង សត្វដែលអញបានសំលាប់សំរាប់ពួកជាងកាត់រោមចៀម ទៅចែកដល់ពួកមនុស្សដែលអញមិនដឹងថា មកពីណាផងឬអី?"[៩]។ នៅក្នុងសម័យព្រះគម្ពីរ សាច់គឺជាភាពប្រណិតដែលគេបរិភោគនៅពេលពិសេស ដូចជាពេលបុណ្យកាត់រោមចៀមនេះអ៊ីចឹងដែរ ។ ដូចគ្នាដែរនេះជាប្រទេសដែលពេញទៅដោយវាលរហោស្ថាន ដូច្នេះទឹកក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ។ ណាបាល ប្រាកដជាមិនចែកចាយនូវភាពស្វាគមន៍រាក់ទាក់របស់ខ្លួនដល់មនុស្សប៉ិនសន្ធំរឿងទាំងអស់នេះទេ!

[៩] ១ សាំយ៉ូអែល ២៥:១០-១១

មនុស្សកំលោះទាំង១០នាក់នេះបានត្រលប់ថយក្រោយ ហើយវិលត្រលប់ទៅរាយការណ៍នូវគ្រប់ទាំងពាក្យពេចន៍ប្រមាថទាំងនេះ ដល់ចៅហ្វាយរបស់ខ្លួនវិញ ។ ដាវីឌមានកំហឹងយ៉ាងខ្លាំង ។ គាត់បានបញ្ជាមនុស្សរបស់គាត់៤០០នាក់ឲ្យក្រវាត់ដាវគ្រប់គ្នាឡើងនោះគេក៏ក្រវាត់ដាវរៀងៗខ្លួន ហើយទុកមនុស្ស ២០០នាក់ទៀតនៅថែរក្សាអីវ៉ាន់ ។

ក្នុងពេលជាមួយគ្នានោះ មានម្នាក់ជាអ្នកគង្វាលចៀមរបស់ ណាបាល បានឮរឿងនេះហើយបានប្រាប់ទៅ អ័ប៊ីកែលដែលជាប្រពន្ធរបស់ ណាបាល នូវអ្វីដែលបានកើតមានឡើង ។ គេបានប្រាប់ពីអ្វីដែល ដាវីឌ បានបញ្ជូនមនុស្សរបស់គាត់ឲ្យទៅជំរាបសួរដល់ណាបាល ប៉ុន្តែម្ចាស់ដ៏ស្កុកស្កម្នាក់នោះ បែរជាឆ្លើយទៅវិញនូវពាក្យប្រមាថមើលងាយ ។ អ្នកគង្វាលចៀមនោះបានបញ្ជាក់ថែមទៀតថា មនុស្សរបស់ដាវីឌបានការពារ ពួកគេបានយ៉ាងល្អក្នុងរយៈពេលប៉ុន្មានខែមុននេះ បើសិនជាលោកស្រី មិនមានសកម្មភាពឲ្យឆាប់រហ័សទេ នោះគ្រោះថ្នាក់នឹងកើតមកដល់លោកម្ចាស់ និង គ្រួរបស់លោក ពីព្រោះគ្មាននរណាម្នាក់អាចទៅឲ្យហេតុផល ដល់ប្តីរបស់លោកស្រីបានឡើយ ។

ដោយប្រើប្រាជ្ញា និង ការយល់ដឹងរបស់នាង អ័ប៊ីកែល បានគិតរកមធ្យោបាយយ៉ាងណា ដើម្បីឲ្យជម្លោះនៅក្នុងហេតុការណ៍នេះមានភាពស្ងប់ស្ងាត់ជាមធ្យោបាយដែលធ្វើឲ្យដាវីឌស្ងប់ចិត្ត ហើយការពារប្តីរបស់ខ្លួន ។ ការទទួលស្គាល់ដាវីឌថាជាអ្នកដែលព្រះបានចាក់ប្រេងតាំង នាងបានដឹងថា កំហឹងទាំងនេះនឹងត្រូវស្ងប់ទៅ ហើយនាងនឹងមិនលើកទឹកចិត្តឲ្យនាំការសងសឹកទុកនៅក្នុងដៃរបស់គាត់នោះទេ ។ ជាងនោះទៅទៀតនាងបានសរសើរថា នាងនឹងទុកឱកាសឲ្យព្រះធ្វើការនៅក្នុងពេលរបស់ព្រះអង្គនិងក្នុងមធ្យោបាយរបស់ព្រះអង្គនៅក្នុងជីវិតប្តីរបស់នាង ។ ទោះបីយ៉ាងណាក៏ដោយ អ័ប៊ីកែល ទទួលស្គាល់ថាសកម្មភាពទាំងឡាយ របស់នាងត្រូវតែថ្វាយកិត្តិយសទៅព្រះជាម្ចាស់ ។ នាងក៏ធ្វើសកម្មភាពភ្លាម ។ នាងក៏ចាប់ផ្តើមចាត់ចែងនំបុ័ង

ស្រា និងសាច់ចៀម លាជ ផ្លែទំពាំងបាយជូរក្រៀម និង ផ្លែល្វាក្រៀមផ្ទុកលើសត្វលានាំទៅ ហើយប្រាប់ឲ្យបាវបំរើរបស់នាងដើរមុខនាង ។ នាងមិនបានប្រាប់អ្វីដល់ប្ដីរបស់នាងទេ ។

ក្នុងខណៈពេលដែលអ័ប៊ីកែល នាំជំនូនទៅឲ្យស្ដេចសោយដោយជិះលើខ្នងលាចុះតាមច្រកភ្នំចំនឹងមុខទ័ពដាវីឌ និង មនុស្សរបស់លោកមកតាមច្រកនោះដែរទល់មុខគ្នា ។ ដាវីឌទើបតែនិយាយជាមួយមនុស្សរបស់លោកថាដែលអញបានថែរក្សាទ្រព្យរបស់ទាំងប៉ុន្មាននៃមនុស្សនេះ ឲ្យគង់វង្សនៅបានក្នុងទីរហោស្ថានឥតមានបាត់អ្វីណាមួយឡើយនោះពិតប្រាកដជាឥតប្រយោជន៍សោះ វាបានប្រព្រឹត្តការអាក្រក់ស្នងនឹងការល្អដល់អញវិញ ។ លោកបានស្បថថានៅពេលព្រឹកនេះលោកនឹងសំលាប់កូនប្រុសៗទាំងអស់របស់ណាបាល ។ លោកចេញមកដើម្បីសងសឹក ។ មនុស្សដូចជា ណាបាល នេះបានបង្ហាញពីភាពឆ្កួតលីលើដោយបដិសេធន៍ព្រះរាជបញ្ជារបស់ព្រះដែលថា " មិនត្រូវសងសឹក ឬ ចងគំនុំគុំគួន និង កូនចៅរបស់សាសន៍ឯងឡើយ គឺត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯងវិញអញនេះជាព្រះយេហូវ៉ា"[១០] ។ លោកបានអោនទៅលើជម្រៅនៃសម័យកាលមុនរបស់ស្ដេចផារោន[១១] ។

អ័ប៊ីកែល និង ដាវីឌបានជួបគ្នាតាមផ្លូវនៅទីនោះ ។ អ័ប៊ីកែលបានសម្រូតចុះយ៉ាងលឿនពីលើខ្នងលា ហើយលុតជង្គង់ក្រាបទៀបជើងលោកដោយផ្កាប់មុខចុះដល់ដីនៅក្នុងអភិវន្ទនាការនៃកាយវិការគោរពផ្ដល់កិត្តិយសនិងការចុះចូលទៅ ចំពោះស្ដេចនៅពេលអនាគតដែលព្រះជាម្ចាស់បានចាក់ប្រេងតាំងជ្រើសឡើង ។ " ឱលោកម្ចាស់ខ្ញុំអើយ សូមឲ្យទោសនោះធ្លាក់មកលើរូបខ្ញុំម្ចាស់វិញចុះ "[១២] យី ! នាងមានវិញ្ញាណសុភាព និង ឆាប់ដឹងខ្លួនល្អណាស់

---

[១០] *លេវីវិន័យ ១៩:១៨*

[១១] *និក្ខមនំ ៧-១១*

[១២] *១សាំយូអែល ២៥:២៤*

ហ្ន៎ ! ពិតហើយប្ដីនាងគួរតែទទួលអ្វីៗទាំងអស់មកលើខ្លួនរបស់គាត់ ប៉ុន្តែអប៊ីកែល បានរៀបចំទទួលអំរែកបន្ទុកនៃការទទួលខុសត្រូវសំរាប់ហេតុការណ៍ធ្ងន់ធ្ងរហួតដល់បាត់បង់ជីវិតទាំងគ្រួនេះ ។ នាងមិនបានគិតគូរពីសុវត្ថិភាព និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ប៉ុន្តែស្ម័គ្រចិត្តលះបង់សេចក្ដីសុខផ្ទាល់ខ្លួនដើម្បីការពារប្ដី និង សមាជិកគ្រួសារដែលមិនដឹងអីដែលកំពុងជួបនូវគ្រោះថ្នាក់ ។ នាងក៏បានគិតអំពីអនាគតរបស់ដាវីឌដែរ ។

" សូមឲ្យខ្ញុំជាបាវស្រីរបស់លោកជំរាបជូនលោកស្ដាប់សិនហើយ សូមស្ដាប់ពាក្យបាវស្រីលោកសិន ។ កុំឲ្យលោកម្ចាស់តាំងចិត្តចំពោះ ណាបាលជាមនុស្សកំណាចនោះឡើយ ត្បិតគាត់ដូចជាឈ្មោះគាត់ពិតមែនគឺគាត់ឈ្មោះណាបាលហើយក៏មានសេចក្ដីចំកួតនោះឯង ឯខ្ញុំជាបាវបំរើស្រីរបស់លោកខ្ញុំឥតបានឃើញពួកកំលោះរបស់លោកម្ចាស់ដែលបានចាត់ទៅនោះទេ ដូច្នេះឱលោកម្ចាស់ខ្ញុំអើយខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ ហើយដោយនូវព្រលឹងលោកដែរថាពួកខ្មាំងសត្រូវរបស់លោកម្ចាស់នៃខ្ញុំ ព្រមទាំងអស់អ្នកដែលរករឿងបង្កើតការអាក្រក់ ដល់លោកនឹងបានដូចណាបាលនោះឯង ដោយព្រោះព្រះយេហូវ៉ាឃាត់លោកមិនឲ្យកំចាយឈាម ហើយមិនឲ្យសងសឹកដោយដៃលោកឡើយ រីឯជំនូននេះដែលខ្ញុំម្ចាស់ជាអ្នកបំរើរបស់លោកបាននាំយកមកជូននោះសូមចែកឲ្យដល់ពួកកំលោះដែលតាមលោកម្ចាស់នៃខ្ញុំមកនោះចុះ ។

" សូមអត់ទោសសេចក្ដីរំលងនេះ ដល់បាវស្រីរបស់លោកផង ! ដ្បិតព្រះយេហូវ៉ានឹងតាំងជំនួរវង្សរបស់លោកម្ចាស់នៃខ្ញុំឲ្យមាំមួនឡើងជាពិតប្រាកដពីព្រោះលោកម្ចាស់នៃខ្ញុំតែងធ្វើសង្គ្រាមដែលព្រះយេហូវ៉ា តម្រូវឲ្យលោក ហើយនឹងគ្មានឃើញសេចក្ដីអាក្រក់ណានៅក្នុងលោកម្ចាស់ឡើយគ្រប់មួយជីវិតរបស់លោក ។

មួយទៀតបើមានមនុស្ស លើកដេញតាមរកប្រហារជីវិតរបស់លោក ក៏ដោយគង់តែជីវិតលោកម្ចាស់នៃខ្ញុំ នឹងបានចងជាប់ក្នុងបាច់នៃជីវិត ជាមួយនឹងព្រះយេហូវ៉ាជាព្រះរបស់លោកដែរ ឯជីវិតរបស់ពួកខ្មាំងសត្រូវរបស់លោកនឹងត្រូវបាត់ទៅដូចជា បាញ់ចេញពីខ្សែដង្ហក់វិញ ។

" រួចកាលព្រះយេហូវ៉ាបានប្រោសលោកម្ចាស់នៃខ្ញុំ តាមគ្រប់ទាំងសេចក្ដីល្អដែលទ្រង់បានមានបន្ទូលពីដំណើរលោក ព្រមទាំងតាំងលោកឡើងឲ្យគ្រប់គ្រងលើសាសន៍អ៊ីស្រាអែល ហើយនោះដំណើរនេះមិនបានជាហេតុឲ្យលោកតូចចិត្តស្ដាយដោយ លោកកំចាយឈាមគេដោយឥត ហេតុ ឬបានសងសឹកដល់គេដោយខ្លួនលោកឡើយ ហើយកាលណា ព្រះយេហូវ៉ា បានប្រោសសេចក្ដីល្អដល់លោកម្ចាស់ នោះសូមទាននឹកចាំពីខ្ញុំជាបាវស្រីរបស់លោកផង "[១៣] ។

អ័ប៊ីកែលបានសុំការអត់ទោសពីដាវីឌ នៅក្នុងការជួបជាមួយនឹងលោក ដោយក្លាហាននិងនិយាយទៅចំពោះលោកក្នុងមធ្យោបាយនេះ ។ នាងបានទទួលកំហុសពីភាពអវត្តមានរបស់នាង ដែលមិនបានផ្ដល់ការរាក់ទាក់នៅពេលដែលមនុស្សរបស់ដាវីឌបានមកដល់ ។ ដូច្នេះបានជានាងធ្វើការសូមទោសជំនួសប្ដីរបស់នាងចំពោះអត្តចរិតមិនល្អ ។ ចាំបាច់ជាងនេះទៅទៀត ទោះបីយ៉ាងណាក៏ដោយគឺនាងបានទទួលស្គាល់ថា ដាវីឌគឺជាអ្នកបំរើដែលព្រះបានចាក់ប្រេងតាំងឲ្យធ្វើជាអ្នកដឹកនាំនៃប្រទេស និង ជាមនុស្ស ដែលប្រយុទ្ធក្នុងសមរភូមិដែលព្រះជាម្ចាស់ប្រទានឲ្យ ។ នាងបានប្រកាសពីបំណងសងសឹកយ៉ាងឆាប់រហ័សរបស់លោកដែលជាកំហុសដ៏មានសក្ដានុពល " មាននៅក្នុងមនសិការរបស់លោក " ទុកដូចជា បន្ទុកមួយដែល ត្រូវការកំចាយឈាម ឬ

---

[១៣] *១សាំយូអែល ២៥:២៨*

ចេញពីការសងសឹកដោយខ្លួនលោកផ្ទាល់"[១៨] ។ ជាមួយការស្វែងយល់ដោយប្រុងប្រយ័ត្នជៀសចេញពីអត្តចរិត និង ការនិយាយលឿនជ្រុលពេកនោះព្រមទាំងបង្ហាញពីភាពប៉ិនប្រសព្វ និងប្រាជ្ញានៅក្នុងការទំនាក់ទំនង របស់នាងជាមួយដាវីឌ ភាពវៃឆ្លាតរបស់អ័ប៊ីកែលបានស្តារស្ថានភាពគ្រោះថ្នាក់ឲ្យត្រឡប់សុខសាន្តវិញ ។ ក្នុងឋានៈជា " អ្នកបំរើ" យ៉ាងតូចទាប នាងបានជួយគំនិតដល់ស្តេចនៅពេលអនាគត ។

ដាវីឌបានតបឆ្លើយដោយសរសើរតំកើងព្រះជាម្ចាស់ ដែលបានបញ្ជូនអ័ប៊ីកែលឲ្យមកជួយធ្វើអន្តរាគមន៍ ។ លោកបានសូមព្រះឲ្យប្រទានព្រះពរដល់នាងសំរាប់ការមានសុភវិនិច្ឆ័យយ៉ាងល្អរបស់នាង ហើយបានជួយទប់លោកចេញពីការក្លាយទៅជាអ្នកមានកំហុសនៃការកំចាយឈាម ឬ សងសឹកដោយខ្លួនឯងជាជាងទុកការសងសឹកនេះថ្វាយដល់ព្រះអម្ចាស់វិញ ។ បន្ទាប់មកលោកបានទទួលជំនូនដែលនាងបាននាំមកនៅផ្ទុកលើខ្នងលានោះ ហើយប្រាប់នាងឲ្យវិលទៅផ្ទះវិញដោយសុខសាន្ត ។ លោកបានទទួលស្គាល់ ពាក្យសុំដីរបស់នាង ហើយសន្យាទទួលអ្វីដែល នាងសំណូមពរ ។

ពេលដែលអ័ប៊ីកែលបានមកដល់ផ្ទះណាបាលបានធ្វើ " ពិធីជប់លៀងយ៉ាងធំមួយ " ដោយខ្លួនឯងហើយគាត់ស្រវឹងស្រាយ៉ាងខ្លាំង ។ នាងមិនបានប្រាប់នូវអ្វីដែលនាងបានធ្វើ រហូតដល់ណាបាលស្វាងស្រានៅពេលព្រឹកឡើង ។ នៅពេលដែលពុំរឿងទាំងអស់នោះរួចមក ពេលនោះលោកក៏ភ័យឡើងតាំងបេះដូង ហើយក៏សន្លប់រឹងស្តូកទៅ ។ ប៉ុន្មានជាដប់ថ្ងៃក្រោយមកលោកក៏ស្លាប់ទៅ ។ ដាវីឌបានដឹងពីមរណៈភាពរបស់ ណាបាល ដាវីឌបានសរសើរតំកើងព្រះជាម្ចាស់ម្តងទៀត ដោយព្រោះទ្រង់បានទំលាក់ទោសទៅលើណាបាលវិញដោយមិនឲ្យលោកប្រព្រឹត្តការអាក្រក់ឡើយ ហើយនាំនូវកំហុសរបស់ណាបាល ចុះនៅលើក្បាលរបស់ខ្លួនផ្ទាល់ ។ បន្ទាប់មកលោក

---

[១៨] ១សាំយូអែល២៥:៣១

បញ្ជូនបាវរបស់លោក ទៅឯអប៊ីកែល នៅឯ កើមែលដោយ ប្រាប់នាងថា ដាវីឌ បានបញ្ជូនពួកគេមកឲ្យទទួលនាងធ្វើជាប្រពន្ធរបស់លោក ។ នៅតែពិតចំពោះអត្តចរិតរបស់នាងអប៊ីកែលក្រាប ចុះនៅចំពោះពួកគេដល់ដី ដោយនិយាយថា នាងប្រុងប្រៀបជាស្រេចដើម្បីបំរើពួកគេ និង លាងជើងឲ្យពួកគេនាងបង្ហាញម្តងទៀតនូវភាពរាក់ទាក់និងភាពជាអ្នកបំរើ ។ នាងបានឡើងលើខ្នងលាជាមួយអ្នកបំរើរបស់នាងប្រាំនាក់ទៀតទៅជាមួយអ្នកនាំសាររបស់ដាវីឌ ហើយក៏ក្លាយទៅជាប្រពន្ធរបស់ដាវីឌតទៅ ។

## ការសញ្ជឹងគិតពិចារណា

រឿងដ៏ខ្លីដែលមានអត្ថន័យនៃអត្តចរិតរបស់មនុស្សចំពោះការជួបប្រទះនិងវិបត្តិផ្តល់ឲ្យយើងនូវគំរូយ៉ាងល្អ អំពីលក្ខណៈសម្បត្តិរបស់មនុស្សដែលបង្ហាញពីកោតខ្លាចព្រះនិងមិនកោតខ្លាចព្រះ ។ ទោះបីយ៉ាងណាក៏ដោយយើងមិនត្រូវដាក់ខ្លួនរបស់យើងទាំងស្រុងចូលទៅក្នុងតំលៃនៃការកោតខ្លាចព្រះដោយ " គិតដូចនេះថានឹងអាចរស់ក្នុងជីវិតល្អនោះឡើយ " ។ ផ្ទុយទៅវិញយើងត្រូវអានរឿងនេះ ដោយពិចារណាពីភាពជាមនុស្សដែលមានលក្ខណៈសម្បត្តិចំណុចខ្លាំង និង ចំណុចខ្សោយពីទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និង ពិតប្រាកដហើយទំនាក់ទំនងជាមួយព្រះជាម្ចាស់របស់នោះឯងសំខាន់ ។ បន្ទាប់មកយើងនឹងចាប់ផ្តើមមើលមកខ្លួនយើងភាពជាមនុស្សផ្ទាល់របស់យើង ។ ជីវិតមនុស្សវាមិនគ្រាន់តែជាជីវសាស្ត្រប៉ុណ្ណោះទេត្រូវតែទាក់ទងជាមួយព្រះ។ យើងត្រូវតែបន្ត ហើយអធិស្ឋានជានិច្ចដោយសួរខ្លួនឯងថា " តើកន្លែងណាដែលព្រះអាចធ្វើការបាន ? " តើទ្រង់ជាអ្នកដឹកនាំជីវិត ឬខ្ញុំដាក់ព្រះអង្គ នៅក្នុងបរិមណ្ឌល ឬក៏ខ្ញុំលុបព្រះអង្គចោលតែម្តង?"។

គ្មានការសង្ស័យឡើយអប៊ីកែលជាអ្នកដែលមានប្រាជ្ញ និង ស្ត្រីដែលមានតំលៃក្រោយមកប្រៀបធៀបទៅនឹង " ប្រពន្ធដែលមានលក្ខណៈសម្បត្តិ

ថ្លៃថ្នូរ "[១៥]។ នាងមានព្រះទុកជាចំណុចកណ្ដាលនៃជីវិតរបស់នាងទ្រង់ គឺជាព្រះអម្ចាស់ជាស្ដេច និងជាចៅហ្វាយរបស់នាង ។ ការគិត និង សកម្មភាពរបស់នាងគឺនៅជុំវិញព្រះជានិច្ច ។ នាងងាយដឹង ហើយមានជំរៅចិត្តយល់ពីអារម្មណ៍អ្នកដទៃ និង រួមចំណែកឈឺឆ្អាលនឹងសេចក្ដីត្រូវការរបស់ពួកគេដឹកនាំពួកគេឆ្ពោះទៅរកសកម្មភាពដ៏ត្រឹមត្រូវ ។

ដាវីឌក៏ជាមនុស្សឆាប់រវាសរវៃដែរ ទោះបីជាលោកមានអារម្មណ៍ឆាប់ខឹងយ៉ាងខ្លាំងទៅលើការបដិសេធន៍របស់ណាបាល ហើយការនេះនាំគាត់ទៅរកសកម្មភាពអាក្រក់ ដែលស្វែងរកការសងសឹក ។ វាជាការគួរឲ្យចាប់អារម្មណ៍ក្នុងការពិចារណាថាហេតុអ្វីបានជាដាវីឌបញ្ចេញសកម្មភាពយ៉ាង ដូច្នេះនៅក្នុងរឿងនេះនៅពេលដែលលោកបានសម្រេចកាលពីមុននោះ ដែលលោកមិនបានឆក់យកឱកាសសងសឹកដល់ស្ដេចសូល [១៦] ហើយមិនត្រឹមតែប៉ុណ្ណោះជួយរក្សាជីវិតស្ដេចសូលទៀតផង នៅក្នុងរឿងជួបប្រទះដូចគ្នា [១៧]។ ហេតុអ្វីបានជាព្រះទ្រង់គឺជាម្ចាស់ជីវិតរបស់ដាវីឌ នៅពេលដែលអនុវត្តជាមួយស្ដេចសូល ប៉ុន្តែដូចជាមានការបាត់បង់សភាពនោះនៅពេលដែលអនុវត្តជាមួយណាបាល ? តើដោយព្រោះតែមនុស្សពីរនាក់នោះមានឋានៈខុសគ្នាឬ ? នៅក្នុងហេតុការណ៍ជាមួយ ណាបាលភាពរួសរាន់របស់លោកបានភ្លេចព្រះរាជបញ្ជារបស់ព្រះឬ?

គឺសេចក្ដីសងសឹកនឹងសេចក្ដីសងគុណនោះគឺស្រេចនូវអញក្នុងកាលដែលយើងគេរអិលភ្លាត ដ្បិតថ្ងៃដែលគេត្រូវអន្តរាយ នោះជិតមកដល់ ហើយការដែលត្រូវមកលើគេនោះជិតមកដល់ហើយ [១៨] ។

---

[១៥] *សុភាសិត ៣១:១០-៣១*

[១៦] *១សាំយូអែល ២៤*

[១៧] *១សាំយូអែល ២៦*

[១៨] *ចោទិ ៣២:៣៥*

ទោះបីជាមានហេតុផលយ៉ាងណាក៏ដោយការឆ្លើយរបស់ដាវីឌ ទៅចំពោះការប្រមាថរបស់ណាបាលគឺត្រូវតែសងសឹកសំលាប់គាត់ និង មនុស្សប្រុសៗទាំងអស់នៅក្នុងគ្រួសាររបស់គាត់មុននឹងថ្ងៃរះឡើង។ តើយើងតែងតែធ្វើយ៉ាងដូច្នេះ ជារឿយៗប៉ុណ្ណាពុះកញ្ជ្រោលឡើងក្នុងសេចក្តីកំហឹងស្វែងរកការតបស្នងវិញ ប្រឆាំងទៅនឹងនរណាម្នាក់ដែលប៉ះពាល់ដល់ យើងសងទៅតាមអ្វីដែលគេវាយមកឲ្យយើង? តែប្រសិនបើ ព្រះជាចំណុចកណ្តាលនៃជីវិតរបស់យើងនោះ ទ្រង់នឹងឆ្លើយសេចក្តីអធិស្ឋានយើង " កុំនាំយើងខ្ញុំទៅក្នុងសេចក្តីល្បួងឡើយ តែសូមប្រោសយើងខ្ញុំឲ្យរួចពីសេចក្តីអាក្រក់វិញ"[១៩]។ ទ្រង់នឹងប្រើមនុស្សផ្សេងទៀត ហេតុការណ៍ផ្សេងទៀតដើម្បីបញ្ឈប់មិនឲ្យយើងធ្វើបាប ។ ទ្រង់ប្រើ អ័ប៊ីកែលដើម្បីបញ្ឈប់ដាវីឌ ។

ដូចដែលយើងសិក្សាពីលក្ខណៈសម្បត្តិនៅក្នុងរឿងនេះក៏ដូចជានៅក្នុងរឿងផ្សេងៗទៀតនៅក្នុងព្រះគម្ពីរ ចូរឲ្យយើងសូមព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងជីវិតយើងដែលមានបំណងចង់បានលក្ខណៈសម្បត្តិដែល កោតខ្លាចព្រះដែលបង្ហាញឲ្យឃើញ នៅក្នុងជីវិតរបស់នាង អ័ប៊ីកែល ភាពសម្បុរសរួសរាយ វៃឆ្លាត គុណធម៌ អត់ធ្មត់ ប្រាជ្ញា ភាពឆាប់ដឹងសង្កេត យល់ខាងវិញ្ញាណ និង ការបង្កើតសន្តិភាព ។ ចូរឲ្យយើងសូមការទាំងអស់នេះតាមរយៈពាក្យរបស់យ៉ាកុប " តែបើអ្នករាល់គ្នាណាខ្វះប្រាជ្ញាមានតែសូមដល់ព្រះដែលទ្រង់ប្រទានដល់មនុស្ស ទាំងអស់ដោយសទ្ធាឥតបន្ទោសផងនោះទ្រង់នឹងប្រទានឲ្យតែត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿឥតសង្ស័យអ្វីសោះ"[២០]។

---

[១៩] *ម៉ាថាយ ៦:១៣*

[២០] *យ៉ាកុប ១:៥-៦*